**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៧៦ អនក្រ.តត

# អនុក្រឹត្យ

# ស្តីពី

# ការបង្កើតថេរសភានៃព្រះពុទ្ធសាសនា

# នៅព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
  បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៧០៤ ចុះថ្ងៃទី១៥/ ០៧/ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រមលេខ ០២ /នស/ ៩៤ ចុះថ្ងៃទី ២០/ ០៧/ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។
- បានឃើញសង្ឃប្រកាសលេខ ៣៣.កសរ.វ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការទទួលស្គាល់ករណីកិច្ចនៃ ចៅអធិការ អនុគណ មេគុណ ដែលអនុសំវច្ឆរមហាសន្និបាតទី១៨ នៃមន្ត្រីសង្ឃសម្រាប់ឆ្នាំ១៩៦២ បានសំរេច ហើយនោះទុកជាករណីកិច្ចធរមាន ដើម្បីបន្តអនុវត្តសម្រាប់គ្រប់គ្រងកិច្ចការពុទ្ធសាសនាតទៅ។
- បានឃើញដំណើរការប្រព្រឹត្តទៅនៃវិស័យព្រះពុទ្ធសាសនានៅព្រះរាជាណាចក្រកម្ពុជា និង ការកើតឡើងនូវអធិករណ៍ជាបន្តបន្ទាប់នៅក្នុងជួរនៃអ្នកបួស ក្នុងព្រះពុទ្ធសាសនា រវាងព្រះសង្ឃ និងព្រះសង្ឃ រវាងព្រះសង្ឃ និងគ្រហស្ថជាបុគ្គល ឬជាសមូហភាពដែលជាហេតុនាំអោយមានផលប៉ះពាល់ដល់ព្រះពុទ្ធសាសនា ជាសាស នា របស់ជាតិ។
- យោងតាមស្មារតីអង្គប្រជុំថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៦ ស្តីពីការបង្កើតថេរសភា នៃព្រះពុទ្ធសាសនានៅព្រះរាជាណាចក្រកម្ពុជា
- តាមសំណូមពររបស់សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី ទេព វង្ស សម្តេចព្រះមហាសង្ឃរាជនៃព្រះរាជា ណាចក្រកម្ពុជា

# ស ម្រេ ច

**មាត្រា១ :** បង្កើតថេរសភានៃព្រះពុទ្ធសាសនាមួយនៅព្រះរាជាណាចក្រកម្ពុជា ដែលជាអង្គការកំពូល សម្រាប់ដោះស្រាយអធិករណ៍នៃពុទ្ធសាសនាដែលមានសមាសភាពដូចខាងក្រោមនេះ:

| | | |
|---|---|---|
| ១. សម្តេចព្រះធម្មលិខិត | **លាស់ ឡាយ** | ប្រធាន |
| ២. សម្តេចព្រះឧត្តមមុនី | **ហេង លាងហោ** | អនុប្រធានទី១ |
| ៣. សម្តេចព្រះវនរ័ត | **ណយ ច្រឹក** | អនុប្រធានទី២ |
| ៤. សម្តេចព្រះពោធិវង្ស | **អំ លឹមហេង** | អនុប្រធានទី៣ |
| ៥. សម្តេចព្រះឧត្តមវង្សា | **មួង រ៉ា** | លេខាធិការ |
| ៦. សម្តេចព្រះឧត្តមបញ្ញា | **ដួង ផង់** | សមាជិក |
| ៧. សម្តេចព្រះឧត្តមចរិយា | **ឈឹង ប៊ុនឈា** | សមាជិក |
| ៨. ព្រះមុនីកោសល | **ហ៊ុល សុវណ្ណ** | សមាជិក |
| ៩. ព្រះសិរីសម្មតិវង្ស | **យឿង យ៉ាត** | សមាជិក |

**មាត្រា២ :** - ថេរសភានៃព្រះពុទ្ធសាសនាមានភារកិច្ចដូចតទៅនេះ

- ជាសហធម្មិកសង្ឃជាន់ខ្ពស់របស់សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី និង សម្តេចព្រះមហាសុមេធាធិបតី ក្នុងបេសកម្មជួយអភិបាលកិច្ចសង្ឃដោះស្រាយរម្ងាប់អធិករណ៍ ដែលកើតមានឡើងនៅ ទូទាំងព្រះរាជាណាចក្រកម្ពុជា។
- ជំនុំជម្រះអធិករណ៍ដែលកើតឡើងរវាង សង្ឃនិងសង្ឃ រវាង សង្ឃនិងគ្រហស្ថ ដែលវិន័យធរ ធម្មធរ អនុគណ មេគុណ សង្ឃនាយក ឬសង្ឃរាជពុំអាចរំងាប់បាន ។
- ចាត់តាំងតំណាងចុះទៅស្រាវជ្រាវ ស្វែងយល់ រកហេតុផលពិតប្រាកដ អំពីប្រភពទំនាស់ អំពីយន្តការដោះស្រាយកន្លងមកធ្វើរបាយការណ៍ច្បាស់លាស់ និងសន្និដ្ឋាន ។
- រកគ្រប់វិធីធ្វើការណែនាំ សម្រុះសម្រួល នូវភាគីបង្កអធិករណ៍អោយយល់គ្នាដោយ ប្រើប្រាស់គ្រប់រូបភាពសិល្បវិធីក្នុងនាមជាសហធម្មិក និង ជាភាតរភាពក្នុងពុទ្ធសាសនមណ្ឌល ។
- ធ្វើការធ្វើការជំនុំពិភាក្សាគ្នាដោយម៉ត់ចត់ច្រើនលើកច្រើនសារ ដោយផ្អែកលើគោលការណ៍ធម្ម វិន័យ និងច្បាប់របស់រដ្ឋ ថ្លឹងថ្លែងគ្រប់ទិដ្ឋភាព ទើបធ្វើសេចក្តីសំរេចកាត់ក្តីជាចុងក្រោយ ដោយធ្វើអោយភាគីនិមួយៗ អាចទទួលយកបានដោយគ្មានការរង្កៀស ។
- ត្រូវមានតម្លាភាពក្នុងការរម្ងាប់អធិករណ៍និមួយៗ ដោយឈរលើទស្សនៈគ្រប់ជ្រុងជ្រោយលើមូលដ្ឋាននៃព្រះវិន័យពុទ្ធសាសនា និងច្បាប់របស់រដ្ឋមិនលុះដោយអំណាចអគតិធម៌ទាំង៤ ។
- ទទួលបំពេញភារកិច្ចផ្សេងៗទៀត ដែលសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី និងសម្តេចព្រះមហាសុមេធាធិបតីតម្រូវអោយជួយដោះស្រាយ ។

**មាត្រា៣ :** - ថេរសភានៃព្រះពុទ្ធសាសនាត្រូវរៀបចំលេខាធិការដ្ឋានមួយ ដឹកនាំដោយសម្តេចព្រះឧត្តមវង្សា មួង រ៉ា និងមានសមាជិកមួយចំនួនជាជំនួយការ។

**មាត្រា៤:** - ថេរសភានៃព្រះពុទ្ធសាសនា មានសិទ្ធិប្រើប្រាស់ត្រាដោយឡែកសំរាប់ដំណើរការ។

**មាត្រា៥ :** - រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រី រដ្ឋលេខាធិការពាក់ព័ន្ធ គ្រប់ខេត្ត ក្រុង និងសមាសភាពដូចក្នុងមាត្រា១ ត្រូវទទួលអនុវត្តតាមអនុក្រឹត្យនេះ។

**មាត្រា៦** : - បទប្បញ្ញត្តិទាំងឡាយណាផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៧** : - អនុក្រឹត្យនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួលៈ

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- ឯកសារ-កាលប្បវត្តិ